**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៨ វេលាម៉ោង ១០:៣០ នាទីព្រឹក នៅទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រួមជាមួយតំណាងក្រសួងមហាផ្ទៃ តំណាងរដ្ឋបាលខេត្តក្រចេះ និងតំណាងរដ្ឋបាលរាជធានីភ្នំពេញ បានទទួលជួបតំណាងប្រជាពលរដ្ឋដែលមកតវ៉ាករណីវិវាទពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ចដែលរាជរដ្ឋាភិបាលបានប្រគល់ជូនទៅក្រុមហ៊ុនចំការកៅស៊ូមេមត់ ស្ថិតនៅឃុំ ២ ធ្នូ ស្រុកស្នួល ខេត្តក្រចេះ។

តំណាងប្រជាពលរដ្ឋទទួលស្គាល់ថាបានចូលទន្ទ្រានកាន់កាប់ដីរដ្ឋដែលបានផ្តល់សិទ្ធិសម្បទានសេដ្ឋកិច្ចជូនក្រុមហ៊ុនចំការកៅស៊ូ មេមត់ ពិតប្រាកដមែន ដោយខ្វះដីបង្កបង្កើនផល។ បន្ទាប់មកក៏បានយល់ព្រមត្រឡប់ទៅមូលដ្ឋានវិញ ដើម្បីបន្តសហការជាមួយអាជ្ញាធរខេត្តក្រចេះ សំដៅពន្លឿនការធ្វើអត្តសញ្ញាណកម្មពីមូលដ្ឋានដើមដែលបងប្អូនរស់នៅអចិន្ត្រៃយ៍ឱ្យបានច្បាស់លាស់ ហើយយល់ព្រមទទួលយកដី តាមទំហំ និងទីកន្លែងតាមការរៀបចំរបស់អាជ្ញាធរខេត្តក្រចេះ។ រាជរដ្ឋាភិបាលយកចិត្តទុកដាក់ដោះស្រាយជូនបងប្អូនដែលមានឈ្មោះក្នុងបញ្ជីអ្នកតវ៉ាដែលខ្វះដីលំនៅឋាន និងដីបង្កបង្កើនផលពិតប្រាកដ ដោយត្រូវដាក់សំណើតាមរយៈអាជ្ញាធរដែនដីសាមី ស្របតាមនីតិវិធីសម្បទានដីសង្គមកិច្ច។

ជាមួយនេះ បងប្អូនប្រជាពលរដ្ឋសន្យាសហការជាមួយអាជ្ញាធរដែនដី ក្នុងការទប់ស្កាត់ការចូលទន្ទ្រានដីរដ្ឋ ការញុះញង់ និងការក្លែងបន្លំផ្តល់ព័ត៌មានមិនពិត ដែលបង្កឱ្យយឺតយ៉ាវដល់ដំណើរការដោះស្រាយ។ ក្នុងករណីមានការបន្តចូលទន្ទ្រានដីរដ្ឋ ញុះញង់ និងក្លែងបន្លំផ្តល់ព័ត៌មានមិនពិត បងប្អូនត្រូវប្រឈមចំពោះមុខច្បាប់ជាធរមាន។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋ និងសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១៤ កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៨